**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខៈ០១៩ /០៨ ក.ណ.ហ អ.គ.គ

# កំណត់ហេតុ ស្តីពី កម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល សិក្ខាសាលានៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ

ឆ្នាំពីរពាន់ប្រាំបី ខែ មេសា ថ្ងៃទី ម្ភៃពីរ វេលាម៉ោងប្រាំបី នៅសាលាខេត្តសៀមរាប មានរៀបចំសិក្ខាសាលាមួយ ក្រោមអធិបតីភាពឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីផ្សព្វផ្សាយកម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល។ ចូលរួមជាគណៈធិបតី ក្នុងឱកាសនោះមាន ឯកឧត្តម ស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាប ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាបបានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈអធិបតី គណៈប្រតិភូនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងថ្នាក់ដឹកនាំមន្ត្រីរាជការនៅតាមមន្ទីរជំនាញផ្សេងៗជុំវិញខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលា ព្រមទាំងថ្លែងអំណរគុណដល់អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹង ធ្វើបទបង្ហាញជូនដល់មន្ត្រីរាជការនៃ អង្គភាពជំនាញផ្សេងៗរបស់ខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង ថែមទៀត អំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកែទម្រង់ច្បាប់ និងតុលាការ ។ ឯកឧត្តមបាន បញ្ជាក់ថា អង្គសិក្ខាសាលានាពេលព្រឹកនេះ គឺត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ ផ្សេងៗនៃការកែទម្រង់ច្បាប់ និងតុលាការជូនមន្ត្រីរាជការក្នុងខេត្ត ខណៈដែលរាជរដ្ឋាភិបាលកំពុងតែធ្វើ ដំណើរឆ្ពោះទៅមុខប្រកបដោយឆន្ទៈដ៏មោះមុត ជាមួយនឹងកម្មវិធីនយោបាយកំណែទម្រង់រដ្ឋ ដែលជាសមាសធាតុគន្លឹះនៃអភិបាលកិច្ចល្អស្ថលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៣ នៃរដ្ឋសភា ។

ជាបន្ទាប់ ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទអន្តរាគមន៍ជម្រាបជូនអង្គសិក្ខាសាលាអំពីដំណើរការនៃការកែ

ទម្រង់ច្បាប់ និង តុលាការ និងការរៀបចំរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានបង្កើតឡើង នៅថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការ គណៈរដ្ឋមន្ត្រី និងឯកឧត្តម ឌិត មន្ទី ប្រធានតុលាការកំពូល ជាសហប្រធាន ។ ឯកឧត្តមបានបង្ហាញជូន អង្គប្រជុំអំពីអង្គភាពផ្សេងៗរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលរួមមានអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ (PCB) បង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ និងអង្គភាពគ្រប់គ្រងគម្រោង ( PMU ) បង្កើតឡើងនៅ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការរបស់ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ឯកឧត្តមបានលើកឡើង ពីគោលដៅនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ក្នុងការបង្កើតផែនការសកម្មភាពចក្ខុវិស័យ ទស្សនាទាន គឺចង់អោយវិស័យច្បាប់ និងតុលាការរបស់យើងមានភាពរឹងមាំ និងជាទីទុកចិត្តរបស់ប្រជាពល ក្នុងការដោះស្រាយទំនាស់ផ្សេងៗ ហើយក៏ដើម្បីទ្រទ្រង់គោលការណ៍សិទ្ធិបុគ្គល ការបែងចែកអំណាចដាច់ពីគ្នា និងនីតិរដ្ឋនៅក្នុងលិទ្ធិប្រជាធិបតេយ្យសេរីតាមរយៈការលើកស្ទួយនូវការរីកចំរើនសេដ្ឋកិច្ចនាំមុខដោយវិស័យ ឯកជន ។ ជាមួយគ្នានោះដែរ ឯកឧត្តមបានជម្រាបជូនអំពីការអនុម័តលើឯកសារស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានអនុម័តនូវកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥។

ឯកឧត្តមប្រធានបានលើកឡើងអំពីមតិសាធារណៈដែលថា ការកែទម្រង់ច្បាប់ និងតុលាការនេះ នៅមាន ការយឺតយ៉ាវ ក៏ប៉ុន្តែឯកឧត្តមប្រធានបានជម្រាបជូនថា យើងមានទិសដៅ និងទស្សនាទាន ច្បាស់លាស់ណាស់ ក្នុងការរៀបចំ កំណែទម្រង់ច្បាប់នេះ គឺដើម្បីបង្កើតនូវវិស័យច្បាប់ និងតុលាការមួយ ដែលអាចជឿទុកចិត្តបាន និងមានស្ថេរភាពសម្រាប់ គោលការណ៍សិទ្ធិរបស់បុគ្គល ការបែងចែកអំណាច ដាច់ពីគ្នា និងនីតិរដ្ឋនៅក្នុងលិទ្ធិ ប្រជាធិបតេយ្យសេរី តាមរយៈការលើកស្ទួយនូវការរីកចំរើនសេដ្ឋកិច្ចជាតិនាំមុខដោយវិស័យឯកជន ។

លោក និល នន់ ប្រធានតុលាការខេត្តសៀមរាប ទាក់ទងនឹងការកែទម្រង់ច្បាប់ និងតុលាការនេះ បានមាន ប្រសាសន៍ផ្ទុយពីមតិរបស់ឯកឧត្តមប្រធាននៅខាងដើមថា កំណែទម្រង់ច្បាប់ និងតុលាការនេះ មិនមែនមានការដំណើរ ការយឺតយ៉ាវនោះទេ តាមពិតគឺមានដំណើរការលឿនពេកទៅវិញទេ ។ ទាក់ទិននឹងបញ្ហានេះលោកបានលើកឧទាហរណ៍ ដូចជាក្រមពីរ ដែលដាក់អោយដំណើរការសព្វថ្ងៃនេះជាដើមថា របត់ នៃការប្រែប្រួលអំពីច្បាប់ឆាប់រហ័សពេក តួយ៉ាងក្រមថ្មីមានចំនួនជាង១០០០មាត្រា ហេតុនេះពាក់ព័ន្ធនឹង ច្បាប់មិនទាន់មានការយល់ច្បាស់លាស់ ហើយការបកស្រាយទៀតសោតក៏មានលក្ខណៈផ្សេងៗគ្នា ។ លោកបានលើកឡើងអំពីការខ្វះខាតមួយចំនួនរបស់តុលាការខេត្តដូចខាងក្រោម ៖

- បញ្ហាធនធានមនុស្ស (មានការខ្វះខាត ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ) សម្រាប់ ខេត្តសៀមរាបយើងមានចៅក្រមតែ ០៧ នាក់រួមទាំងព្រះរាជអាជ្ញា ដើម្បីចាត់ការរឿង ក្តីចំនួន២៩៦០រឿង ។ លោកបានបញ្ជាក់ចំពោះការចាត់ការរឿងក្តីនេះ

មិនមែនជារឿងងាយ ស្រួលនោះទេ អាចមានរឿងខ្លះចំណាយពេលដោះស្រាយរហូតដល់ទៅ០៦ខែទើបចប់ ។

- បញ្ហាគ្មានយន្តការអធិការកិច្ច ( អធិការកិច្ចដោយចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា) ដែលជា ហេតុធ្វើអោយមានការឃុំខ្លួនលើសពេលវេលា
- យន្តការថ្មីមួយទៀត យើងបានធ្វើមួយជំហ៊ានហើយ ប៉ុន្តែមិនទាន់បានជោគជ័យ គឺយន្តការបញ្ជូន ទទួលឯកសារដីកាផ្សេងៗ ដោយប្រៃសនីយ៍ ។ ច្បាប់រដ្ឋប្បវេណីដែលកំណត់អោយភាគីបង់លុយ រមែងជួបប្រទៈការលំបាក និងមានការពិបាករកអាស័យដ្ឋាន (ផ្លាស់ប្តូរ ទីលំនៅ)
- ចំពោះក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌថ្មី បើសិនជាមិនមានមូលដ្ឋានគ្រឹះរឹងមាំផ្នែកច្បាប់នេះទេ ការសិក្សាស្រាវជ្រាវអំពីច្បាប់ទាំងអស់នេះ ប្រហែលជាជួបប្រទៈបញ្ហាខ្លាំងមែនទែន ។

លោកបានធ្វើការប្តេជ្ញាចិត្ត ក្នុងការធ្វើការកែទម្រង់លើវិស័យនេះក្នុងខេត្តសៀមរាប អោយបានប្រសើរឡើង ។ លោកបានគិតថា រហូតមកដល់ពេលនេះតុលាការខេត្តក្រុងមិនទាន់បានរៀបចំបទដ្ឋានអោយបានល្អស្របតាមគតិយុត្តិ និងមិនទាន់មានបទដ្ឋានស្តីអំពីរចនាសម្ព័ន្ធធ្វើអោយបានល្អទេ និយាយរួមគឺរដ្ឋបាលតុលាការ ។

លោកបានមានប្រសាសន៍បន្តទៀតថា ការផ្លាស់ប្តូរចៅក្រមបច្ចុប្បន្ននេះ គឺគ្រាន់តែជារូបភាពខាងក្រៅប៉ុណ្ណោះ ឯបញ្ហាការងារផ្សេងៗ ដូចជាការបិទបញ្ជី បំពេញឯកសារបន្ថែមអោយបាន ចប់សព្វគ្រប់មុននឹង ផ្លាស់ការងារក្នុងអាណត្តិរបស់ខ្លួនពុំបានធ្វើដោយត្រឹមត្រូវនៅឡើយទេ ។ លោកបានជម្រាបផងដែរថា កាលលោកបំពេញការងារនៅខេត្ត បាត់ដំបង លោកបានចាត់ការរឿងព្រហ្មទណ្ឌនៅសល់តែ៤៨សំណុំរឿងតែប៉ុណ្ណោះ ចំណែករឿងរដ្ឋប្បវេណីនៅសល់៣សំណុំរឿង ។ ប៉ុន្តែមកដល់ខេត្តសៀមរាបនេះ មានរឿងក្តីព្រហ្មទណ្ឌដែល មិនទាន់ដោះស្រាយរួចចំនួន ៥៥៥ករណី និងរដ្ឋប្បវេណីចំនួន ៤៣៥ ករណីផងដែរ ។ លោកបានសំណូមពរ អោយកំណត់រចនាសម្ព័នតុលាការក៏ដូចជា រដ្ឋបាលតុលាការយន្តការចាត់រឿងក្តី និងយន្តការចាត់ការភស្តុតាង ។ ចំពោះបញ្ហារតនាគារលោក បានស្នើសុំអោយមានការសហការជាមួយព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការបង់ប្រាក់ឬពន្ធផ្សេងៗទាក់ទងនឹងវិស័យតុលាការនេះដើម្បីបង់ចូលថវិការដ្ឋ ។ ចំណែកប្រៃសនីយ៍លោកបាន សុំអោយជួយសហការ និងជួយជំរុញការងារអោយកាន់តែប្រសើរថែមទៀត ។

ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានស្វាគមន៍ចំពោះរបាយការណ៍អំពីស្ថានភាពជាក់ស្តែង របស់តុលាការខេត្តសៀមរាប និងបានធ្វើការសរសើរលើកទឹកចិត្តអោយបន្តការងារកំណែទម្រង់ច្បាប់ និងតុលាការស្របតាមទិសដៅ របស់រាជរដ្ឋាភិបាលនេះអោយបានកាន់តែខ្លាំងក្លាថែមទៀត ។ ជាបន្ទាប់ឯកឧត្តមបានធ្វើបទបង្ហាញអំពីភាពជឿនលឿននៃការអនុវត្តកម្មវិធីសកម្មភាព យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការកម្ពុជាទៅតាមទិសដៅជាយុទ្ធសាស្ត្រទាំង៧ ។ ដោយសកម្មភាពជាអាទិភាព មានច្រើនពេក

សរុបសកម្មភាពនោះទាំងអស់៩៧ ឯកឧត្តម បានសុំការ អនុញ្ញាតិពីអង្គប្រជុំលើកយកតែចំណុចខ្លះៗ មក បង្ហាញជូនដូចខាងក្រោម ៖

១- ទិសដៅជាយុទ្ធសាស្រ្តទី១ ៖ **ស្តីពីការការពារសិទ្ធិសេរីភាពរបស់បុគ្គល** ចំណុចសំខាន់ក្នុងទិសដៅនេះ គឺការបង្កើនការយល់ដឹងអំពីសិទ្ធិមូលដ្ឋាន និងពលរដ្ឋវិជ្ជា។ ទិសដៅជាយុទ្ធសាស្រ្តទី១ មានចំនួន ១៩ សកម្មភាព ក្នុងនោះមានសកម្មភាព រយៈពេលខ្លី ចំនួន ០៥ សកម្មភាពចំណែករយៈពេលមធ្យម មានចំនួន ០៦ សកម្មភាព និង សកម្មភាពរយៈពេល វែងមានចំនួន ០៨ សកម្មភាព ។

2- ទិសដៅជាយុទ្ធសាស្រ្តទី២ ៖ **ស្តីពីធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់** ឯកឧត្តមមាន ប្រសាសន៍ថា យើងបានអនុម័តច្បាប់ចំនួន ១១៨ច្បាប់ នៅក្នុងអាណត្តិទី៣ នៃ រដ្ឋសភានេះ ក្នុងនោះមាន ច្បាប់ជាមូលដ្ឋានសម្រាប់តុលាការដូចជាក្រម នីតិវិធី រដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ។

3- ទិសដៅជាយុទ្ធសាស្រ្តទី៣ស្តីពីការផ្តល់លទ្ធភាពអោយទទួលបានព័ត៌មានច្បាប់ និង **តុលាការអោយកាន់តែប្រសើរឡើង** បច្ចុប្បន្ននេះយើងកំពុងតែសហាការជាមួយបារាំង និង UNDP ធ្វើយ៉ាងណា អោយច្បាប់នានាបានទៅដល់ប្រជាពលរដ្ឋ ដោយមាន អគ្គនាយកដ្ឋានរាជកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាអ្នកដែលកំពុងធ្វើកិច្ចការ នេះយ៉ាងសកម្ម។

4- ទិសដៅជាយុទ្ធសាស្រ្តទី៤ស្តីពីការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃរឿងក្តី **និងសេវាពាក់ព័ន្ធ** ការងារគន្លឹះក្នុងយុទ្ធសាស្រ្តនេះ គឺការផ្តល់មេធាវីជូនជនក្រីក្រ ការបង្កើនសេវាជំនួយផ្នែកច្បាប់ និងតំណាងផ្នែកច្បាប់អោយបានដល់ប្រជាពលរដ្ឋទាំងអស់ ។ គណៈមេធាវីមាននាយកដ្ឋានមួយទទួល បន្ទុករឿងនេះ ហើយអង្គភាពគ្រប់គ្រងគម្រោងបានសហការជាមួយ EWMI (UsAid) ធ្វើការសិក្សាស្ទង់មតិ អំពីជំនួយផ្នែកច្បាប់នេះ រួចហើយដែរ ។

5- ទិសដៅជាយុទ្ធសាស្រ្តទី៥ ៖ **ពង្រឹងសេវាយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវា អយ្យការ ៖** ការងារដែលមមាញឹកក្នុងទិសដៅនេះ គឺការរៀបចំតុលាការគំរូ ក្រោម ជំនួយឧបត្ថម្ភរបស់ UsAid និង CCJAP

6- ទិសដៅជាយុទ្ធសាស្រ្តទី៦ ៖ **បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ទាក់ទងនឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ សហការជាមួយ UNDP បានសិក្សារៀបចំ និងបង្កើតមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌នៅតាមស្រុកចំនួន ០៤ នៅខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង នឹងគ្រោងបន្តទៅខេត្តដ៏ទៃទៀតបង្គ្រប់ចំនួន២០ ។

7- ទិសដៅជាយុទ្ធសាស្រ្តទី៧ស្តីពីការពង្រឹងស្ថាប័នវិស័យច្បាប់ **និងតុលាការដើម្បីបំពេញអាណត្តិខ្លួនបានសម្រេច** ។ ការងារដែលមមាញឹកក្នុងទិសដៅនេះ គឺការរៀបចំសៀវភៅណែនាំសម្រាប់យើងទាំងមូល និងការបណ្តុះបណ្តាលអ្នកពាក់ព័ន្ធ ដើម្បី

បង្កើនល្បឿននៃកំណែទម្រង់ ហើយនឹងការរៀបចំប្រព័ន្ធសូចនាករតាមដានការអនុវត្តកំណែទម្រង់ ។

លោក ចៅ សែន នាយករងខុទ្ទកាល័យខេត្តសៀមរាប បានមានប្រសាសន៍ថា ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌បានចេញសេចក្តីប្រកាស ស្តីពីការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុក ចំណែកខេត្តសៀមរាប មានមណ្ឌលសេវាកម្មយុត្តិធម៌ចំនួន០៦ស្រុក ដូច្នេះលោកបានស្នើសុំអោយមានការបណ្តុះបណ្តាលក្នុងការជួយដោះស្រាយវិវាទ និងសុំអោយបង្កើតសាលាដំបូងនៅខេត្តឧត្តរមានជ័យផងដែរ ។ មិនតែ ប៉ុណ្ណោះលោកបានស្នើអោយមាននីតិវិធីច្បាស់លាស់ក្នុង ការដោះស្រាយវិវាទ ដែលពាក់ព័ន្ធទៅសមត្ថកិច្ចដែលសុរិយោដីថ្នាក់ជាតិ ថ្នាក់ ខេត្ត ស្រុក ព្រមទាំងមន្ទីរអធិការកិច្ច ទំនាក់ទំនងសភា និងព្រឹទ្ធសភា ។ ទាក់ទងនឹងការបង្កើតមណ្ឌលសេវាកម្មថ្នាក់ ស្រុក លោកមានប្រសាសន៍ថា គួរកំណត់តួនាទីរបស់គាត់អោយ បានច្បាស់លាស់ ថាតើអាចដោះស្រាយបានត្រឹមណា ?

ឯកឧត្តម ស៊ុយ ម៉ុងលាង បានឆ្លើយតបនឹងលោក ចៅ សែន ថា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានជូនយោបល់ទៅក្រសួងយុត្តិធម៌ ស្តីអំពីតួនាទីរបស់មណ្ឌលយុត្តិធម៌ស្រុកហើយដោយមានពីរកំរិត ៖ ទី១-ធ្វើការផ្សព្វផ្សាយច្បាប់ ទី២-ធ្វើការដោះស្រាយត្រូវមានកំរិត និងស្នើសុំអោយក្រសួងយុត្តិធម៌ ចេញប្រកាស់អោយបានជាក់លាក់ស្តីពីកំរិតតួនាទីនេះ (ការកំរិតតួនាទីដែលត្រូវដោះស្រាយ) ។ ចំណែកការទាមទារការបណ្តុះបណ្តាលនោះវិញ ឯកឧត្តមប្រធានបានគាំទ្រ ហើយនឹងលើកយកសំណើនេះជូនទៅក្រសួងយុត្តិធម៌ ចំពោះបញ្ហាបែងចែកអំណាចអោយ បានច្បាស់លាស់ស្តីពីតួនាទីនោះ ឯកឧត្តមបានមានប្រសាសន៍ថា ក្នុងពេលនេះខាងក្រុមប្រឹក្សាកំពុងតែធ្វើការរៀបចំហើយក្នុងរឿងនេះ ។

លោក និល នន់ បានលើកឡើងថា ការស្នើសុំអោយមានការបង្កើតតុលាការឧត្តរមានជ័យនោះ លោកបានស្នើសុំទៅគណៈរដ្ឋមន្ត្រីហើយ ។ ចំណែកបញ្ហាវិវាទសមត្ថកិច្ចពីរប្រការសំខាន់ គឺត្រូវញែករវាងដែន សមត្ថកិច្ចរបស់ក្រសួងអោយបានច្បាស់លាស់ និងចែកអោយដាច់ដើម្បីកុំអោយជាន់ សមត្ថកិច្ចគ្នា ។ លោកបាន គាំទ្រផងដែរចំពោះការចោទសួររបស់លោកនាយករងខុទ្ទការល័យខេត្តសៀមរាប ដែលបានលើកឡើងខាងលើនោះ ។ មណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុក និងសុរិយោដីនោះ មានតួនាទីដោះស្រាយបញ្ហាដីធ្លីដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ ។ ចំណែកឯការដោះស្រាយវិវាទរបស់មន្ត្រីសេវាកម្មយុត្តិធម៌ថ្នាក់ស្រុក គឺជាវិវាទតូចតាច វិវាទខ្ចីបុលគ្នា ក្រៅពីវិវាទព្រហ្មទណ្ឌ ។

សំណួរសួរថា នៅពេលគូជម្លោះពីររូបផ្ទែកដីធ្លី ក្រោយពីការស៊ើបសួររួចហើយ បានដឹងថាភាគីណាមួយជាអ្នករំលោភយ៉ាងពិតប្រាកដ តើតុលាការសំរេចកាត់ក្តីអោយម្ចាស់ដីយ៉ាងដូចម្តេច ? តើចំពោះភាគីដែល ជាអ្នករំលោភគេនោះ តុលាការកាត់ក្តីអោយយ៉ាងដូចម្តេចដែរ ?ហើយបើដាក់ទោសទណ្ឌទៅលើភាគីរំលោភគេនោះ បែបណា និងរយៈពេលនៃការជំនុំជំរះត្រូវស៊ីពេលប៉ុណ្ណា ? ។ ជា

សំណូមពរ គឺប្រជាពលរដ្ឋចង់អោយ មានការកាត់ក្តីប្រកបដោយតម្លាភាព និង យុត្តិធម៌ពិតប្រាកដ មិនមានភាពលំអៀង ។

លោក និល នន់ បានមានប្រសាសន៍ថា យើងរៀបចំសិក្ខាសាលានេះឡើង គឺដើម្បីអោយមានតុលាការនៅជិតប្រជាពលរដ្ឋមានតម្លាភាព និងមានការកាត់ក្តីប្រកបដោយគតិយុត្តិធម៌នោះតែម្តង ទាំងនេះក៏ជាគោលបំណងផ្ទាល់ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលកំពុងតែដំណើរការស្រាប់ ហើយនៅក្នុងនោះ មានក្រមសីល ធម៌របស់ចៅក្រមផងដែរ ។ ឆ្លើយតបនឹងសំណួរខាងលើនេះ លោកបានជម្រាបថា ទាក់ទិននឹងជម្លោះដីធ្លីនោះ មានពីររឿងគឺ ជារដ្ឋប្បវេណី និងព្រហ្មទណ្ឌ ប្រសិនបើការរំលោភដីសាធារណៈ ដោយប្រើប្រាស់កម្លាំងបាយនោះគឺមានទោសព្រហ្មទណ្ឌហើយ ។ ចំណែករឿងរដ្ឋប្បវេណីវិញ លុះត្រាតែមាន ពាក្យបណ្តឹងទើបតុលាការចាត់ការបាន ចំពោះរយៈពេលតាមធម្មតារឿងជំនុំជំរះគឺរយៈពេល១ពេល ឬក៏មួយថ្ងៃតែប៉ុណ្ណោះ រីឯការចាត់ការរឿងក្តីវិញទាំងព្រហ្មទណ្ឌ និងរដ្ឋប្បវេណីជាមធ្យម មានរយៈពេល០៦ខែ ។

លោក កុក ជាយុទ្ធថន ប្រធានមន្ទីរវប្បធម៌ខេត្ត បានមានមតិយោបល់ថា ក្នុងសង្គមបច្ចុប្បន្នប្រជាពលរដ្ឋដែលរងនូវភាពអយុត្តិធម៌ និងចាញ់ក្តីភាគច្រើនជាពលរដ្ឋស្លូតត្រង់ និងក្រីក្រគ្មានបក្សពួកគ្មានអំណាចដូច្នេះ តើច្បាប់ដាក់ទោសជនល្មើស និងមន្ត្រីស៊ីសំណូកសូកប៉ាន់ ដែលជាអ្នកចេះច្បាប់បែរជាអង្គុយ លើច្បាប់នោះមានប្រសិទ្ធិភាពដល់កំរិតណា ? ជាសំណូមពរលោកមានប្រសាសន៍ថា បើចង់អោយកំណែទម្រង់ច្បាប់នេះ មានប្រសិទ្ធិភាពទៅអនាគតក្នុងសង្គមខ្មែរ គួរតែជ្រើសរើសមន្ត្រីតុលាការមានទាំងសមត្ថភាព និង គុណធម៌ ដែលចេះគិតពីសុខទុក្ខរបស់ប្រជាពលរដ្ឋ ជាចម្បង ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍ថា ទិសដៅកំណែទម្រង់ច្បាប់ និងតុលាការ គឺខិតខំដោះស្រាយបញ្ហានេះដើម្បីកុំអោយកើតមាន ហើយដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។ ឯកឧត្តម ក៏លើកឡើងអំពីប្រសិទ្ធិភាព នៃការដោះស្រាយរបស់តុលាការ ដោយមានប្រសាសន៍ថា តាមទិសដៅរបស់យើង គឺអោយមានប្រសិទ្ធិភាពមួយរយភាគរយ ប៉ុន្តែតាមភាពជាក់ស្តែងមិនដឹងថាបានដល់កំរិតណាទេ ។ ឯកឧត្តម បានមានប្រសាសន៍បន្ថែមថា យើងបានខិតខំផ្តល់កម្មសិក្សារបស់ចៅក្រមដោយយកគំរូមកពីប្រទេសបារាំង ជាពិសេសពី Bordeaux ដែលជាសាលាមានបទពិសោធន៍ល្បីល្បាញពេញទាំងអឺរុប ផ្នែកតុលាការនេះ ។ ទាក់ទងនឹងអ្នកបំរើការងារនៅលើច្បាប់ហើយបែរជាមិនគោរពច្បាប់នោះវិញ នៅក្នុងក្រមព្រហ្មទណ្ឌថ្មីរបស់យើងក៏មានចែងអំពីទោសបញ្ញត្តិផ្សេងៗអស់ហើយ ។

នៅទីបញ្ចប់ឯកឧត្ដម ស៊ុយ ម៉ុងលាង បានធ្វើការបូកសរុបលទ្ធផលនៃអង្គសិក្ខាសាលា និងធ្វើការវាយតម្លៃខ្ពស់ចំពោះការចូលរួមមតិដ៏ផុសផុលរបស់អង្គប្រជុំ ហើយឯកឧត្តមក៏បានកោតសរសើរផងដែរថា អង្គសិក្ខានៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យនេះពិតជាមានសារៈសំខាន់

ណាស់ដោយមានវាគ្មិនដែល ជាប្រធានតុលាការខេត្ត ពោរពេញទៅដោយសមត្ថភាព និងបទពិសោធន៍យ៉ាងច្រើនបានមកចូលរួមពិភាក្សា និងផ្លាស់ប្តូរយោបល់ក្នុងឱកាសដ៏ល្អ វិសេសវិសាលនេះ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០៨*

បានឃើញ និងឯកភាព
គណៈធិបតីនៃអង្គសិក្ខាសាលា

អ្នកធ្វើរបាយការណ៍

**ស៊ុយ ម៉ុងលាង**

**សេង វ៉ាន់ដា** **ស៊ុន សិរីវុធ**